**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ :០២៨/២១ សជណ

ថ្ងៃព្រហស្បតិ៍ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលសំណាកតេស្តរកវីរុសកូវីដ-១៩ នៅរាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្នុងទិសដៅអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាព **រដ្ឋបាលរាជធានីភ្នំពេញ សហការជាមួយក្រសួងសុខាភិបាល និង អនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថាមានផ្ទុកជំងឺកូវីដ-១៩** បានជំរុញការប្រមូលយកសំណាកតេស្តរកវីរុសកូវីដ-១៩ នៅរាជធានីភ្នំពេញ ដោយផ្តោតសំខាន់លើតំបន់ដែលមានការផ្ទុះវិជ្ជមានជំងឺកូវីដ-១៩ ច្រើនករណី ក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ។

ក្នុងន័យនេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបដល់បងប្អូនអាជីវករ បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋទូទៅដែលមានអាការៈក្តៅខ្លួន ក្អក-កណ្តាស់ ពិបាកដកដង្ហើម ឬ សង្ស័យមានជាប់ពាក់ព័ន្ធអ្នកជំងឺកូវីដ-១៩ **សូមអញ្ជើញទំនាក់ទំនងជាមួយមូលដ្ឋានសង្កាត់ដែលខ្លួនរស់នៅ ដើម្បីស្នើសុំលិខិតអនុញ្ញាតធ្វើដំណើរទៅកាន់ទីតាំងប្រមូលយកសំណាកដែលនៅជិតលំនៅឋានរបស់ខ្លួនបំផុត** រួមមាន៖

១- វិទ្យាល័យចាក់ទុក ក្នុងសង្កាត់វាលវង់ ខណ្ឌ៧មករា

២- វិទ្យាល័យបឹងត្របែក ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

៣- សាលាបឋមសិក្សាសុភមង្គល ក្នុងសង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ

៤- វិហារព្រះយេស៊ូ ក្នុងសង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ

៥- ទីតាំងបណ្តោយផ្លូវខ្វាងង្វៀប ជិតរោងចក្រឌីនហាន ក្នុងសង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ

៦- ដីឡូត៍ ខាងក្រោយផ្សារឯករាជ្យ៣ ក្នុងសង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ

៧- មណ្ឌលថែទាំជីវិត ក្នុងសង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ

៨- និង ទីតាំងមួយចំនួនទៀតកំពុងរៀបចំ ដែលរដ្ឋបាលរាជធានីភ្នំពេញនឹងជូនដំណឹងពេលក្រោយទៀត។

ទន្ទឹមនឹងនេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដល់រដ្ឋបាលសង្កាត់ទាំង **១០៥ នៃខណ្ឌទាំង ១៤ ត្រូវរៀបចំមន្ត្រីប្រចាំការដើម្បីផ្តល់ "លិខិតអនុញ្ញាត" ជូនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលត្រូវទៅធ្វើតេស្តយកសំណាក តាមទម្រង់នៃលិខិតអនុញ្ញាតដែលបានភ្ជាប់មកជាមួយស្រាប់។** ដោយឡែក ចំពោះបងប្អូនប្រជាពលរដ្ឋ ដែលត្រូវអញ្ជើញទៅទំនាក់ទំនងជាមួយមូលដ្ឋានសង្កាត់ និងត្រូវធ្វើដំណើរទៅកាន់ទីតាំងធ្វើតេស្តយកសំណាក សូមមេត្តាអនុវត្តនូវកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ដោយត្រូវប្រកាន់ខ្ជាប់ជានិច្ចនូវវិធានការ **"៣ ការពារ និង ៣ កុំ"** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមបងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- រដ្ឋបាលខណ្ឌទាំង១៤
- គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  "ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខណ្ឌ........................................
រដ្ឋបាលសង្កាត់..............................

## លិខិតអនុញ្ញាត

**យើងចៅសង្កាត់..........................................**

ត្រូវបានអនុញ្ញាតឱ្យឈ្មោះ..................................................................................ភេទ..............
លេខទូរស័ព្ទ........................................កាន់អត្តសញ្ញាណប័ណ្ណលេខ................................................
អាសយដ្ឋានផ្ទះលេខ........................ផ្លូវលេខ........................ភូមិ.......................................សង្កាត់
.......................................ខណ្ឌ......................................រាជធានីភ្នំពេញ។

អាចធ្វើដំណើរទៅធ្វើតេស្តយកសំណាកករកវីរុសកូវីដ-១៩ នៅទីតាំង..................................................
ក្នុងថ្ងៃទី............ខែ............ឆ្នាំ២០២១ ដោយប្រើប្រាស់មធ្យោបាយ (ម៉ូតូ ឬ ឡាន) ផ្លាកលេខ......................
ដែលមានអ្នករួមដំណើរ (ក្នុងករណីប្រសិនបើមាន) ចំនួន............នាក់ (ស្រី.........នាក់) ។

**សូមអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលស្គាល់ និងជួយសម្របសម្រួលជូន បងប្អូនប្រជាពលរដ្ឋដែលមានឈ្មោះខាងលើអាចធ្វើដំណើរទៅធ្វើតេស្តយកសំណាកដោយក្តីអនុគ្រោះ។**

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស............
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១
**ចៅសង្កាត់**